ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៧៥ អយក.ស៊ាន

# សេចក្តីណែនាំប្រតិបត្តិស្តីពី
# វិធានការសុខភាព និងសុវត្ថិភាព
# សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
# សម័យប្រឡង៖ ២៧ ធ្នូ ២០២១

ក្នុងគោលបំណងលើកកម្ពស់ការថែទាំសុខភាព និងសុវត្ថិភាពសម្រាប់គណៈមេប្រយោគ គណៈកម្មការនានា និងបេក្ខជន អំឡុងពេលនៃដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង៖ ២៧ ធ្នូ ២០២១ ក្រសួងអប់រំ យុវជន និងកីឡាសូមធ្វើការណែនាំដល់អង្គភាពក្រោមឱវាទទីស្តីការក្រសួង មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដែលត្រូវបានកំណត់ និងជ្រើសរើសយកធ្វើជាមណ្ឌលប្រឡង ជាគណៈមេប្រយោគ និងជាប្រធានមណ្ឌលប្រឡង ត្រូវអនុវត្តតាមគោលការណ៍ណែនាំប្រតិបត្តិដូចខាងក្រោម៖

## ក. ការបង្កើតយន្តការ

### ១- អនុគណៈកម្មការទទួលបន្ទុកការងារសុខភាព

គណៈមេប្រយោគទូទាំងប្រទេស ត្រូវចាត់តាំង អនុគណៈកម្មការទទួលបន្ទុកការងារសុខភាព ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- តាមដាន និងវាយតម្លៃលើស្ថានភាព ការរក្សាអនាម័យ និងសុវត្ថិភាពក្នុងការរៀបចំមណ្ឌលសំណេរ មណ្ឌលកំណែ និងមណ្ឌលបូកស្រង់ពិន្ទុដោយកុំព្យូទ័រ
- តាមដាន និងវាយតម្លៃលើដំណើរការអនុវត្តវិធានសុខភាព និងសុវត្ថិភាព ចំពោះបេក្ខជន គណៈមេប្រយោគ អនុរក្ស អប្បមាទ គណៈកម្មការនានា និងអ្នកពាក់ព័ន្ធក្នុងដំណើរការប្រឡង
- ឆ្លើយតបចំពោះសំណើ និងរាល់បាតុភាពនៃការលេចឡើង ករណីសង្ស័យពាក់ព័ន្ធបញ្ហាសុខភាពសាធារណៈ នៅតាមមណ្ឌលសំណេរ មណ្ឌលកំណែ និងមណ្ឌលស្រង់បូកពិន្ទុ
- ស្នើសុំកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ ភ្នាក់ងារសុខាភិបាល ដើម្បីចាត់វិធានការសង្គ្រោះ និងវិធានការសុវត្ថិភាពស្របតាមវិធានវេជ្ជសាស្ត្ររបស់ក្រសួងសុខាភិបាល នៅក្នុងដំណាក់កាលសំណេរ កំណែ និងដំណាក់កាលស្រង់បូកពិន្ទុដោយកុំព្យូទ័រ
- បូកសរុបរបាយការណ៍អំពី ករណីសង្ស័យ និងការដាក់ចេញនូវវិធានការឆ្លើយតបចំពោះការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ក្នុងអំឡុងពេលដំណើរការប្រឡង ព្រមទាំងរាយការណ៍ និងសុំការសម្រេចពីគណៈមេប្រយោគទូទាំងប្រទេស ក្នុងករណីចាំបាច់។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

## ២- ក្រុមការងារទទួលបន្ទុកសុខភាព ប្រចាំរាជធានី ខេត្ត

គណៈមេប្រយោគទូទាំងប្រទេសប្រចាំរាជធានី ខេត្ត ត្រូវចាត់តាំង ក្រុមការងារទទួលបន្ទុកសុខភាព សម្រាប់ដំណើរការប្រឡងនៅតាមរាជធានី ខេត្ត ដោយមានសមាសភាពចូលរួមពី តំណាង០១រូប នៃគណៈមេប្រយោគទូទាំងប្រទេសប្រចាំរាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ឬតំណាង មន្ត្រីសុខាភិបាល និងអង្គភាពពាក់ព័ន្ធ។ ក្រុមការងារទទួលបន្ទុកសុខភាពប្រចាំរាជធានី ខេត្ត មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំអនុវត្តវិធានការសុខភាព នៅតាមមណ្ឌលប្រឡងនានា ក្នុងទីតាំងភូមិសាស្ត្ររបស់ខ្លួន
- ចាត់តាំងភ្នាក់ងារសុខាភិបាល ដើម្បីសហការជាមួយគណៈមេប្រយោគនៅតាមមណ្ឌលប្រឡង ធ្វើការស្ទង់កម្ដៅ និងផ្ដល់ការបញ្ជាក់សុខភាពជូនដល់គណៈមេប្រយោគប្រឡងនិងបេក្ខជន នៅក្នុងពេលដែលបេក្ខជនមកពិនិត្យមើលឈ្មោះ នៅមណ្ឌលប្រឡង នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ ចាប់ពីម៉ោង ៩:០០ នាទីព្រឹកតទៅ
- រៀបចំរថយន្តសង្គ្រោះ និងភ្នាក់ងារសុខាភិបាលប្រចាំការ ដោយមានបំពាក់សម្ភារៈចាំបាច់ សម្រាប់សង្គ្រោះបឋម នៅតាមមណ្ឌលប្រឡង ក្នុងរាជធានី ខេត្ត និងក្រុង ស្រុកមួយចំនួន ដើម្បីជួយសង្គ្រោះដល់បេក្ខជន និងគណៈមេប្រយោគ ដែលមានបញ្ហាសុខភាព ក្នុងដំណើរការសំណេរ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១
- ណែនាំដល់មណ្ឌលសំណេរ ឱ្យត្រួតពិនិត្យបេក្ខជនដែលបានប៉ះពាល់ផ្ទាល់ជាមួយអ្នកវិជ្ជមានកូវីដ-១៩ និងស្ថិតនៅក្នុងកំឡុងពេលចត្តាឡីស័ក និងរៀបចំការស្ទង់កម្ដៅបេក្ខជនទាំងអស់ មួយថ្ងៃមុនដំណើរការសំណេរ។ ចំពោះបេក្ខជនដែលស្ថិតនៅក្នុងកំឡុងពេលចត្តាឡីស័ក និងបេក្ខជនដែលមានកម្ដៅលើសពី ៣៧,៥អង្សាសេ ឬមានរោគសញ្ញាដូចជាក្អក ហៀរសំបោរ ឈឺបំពង់ក ពិបាកដកដង្ហើម ត្រូវធ្វើតេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩ នៅទីតាំងសុខាភិបាលដែលកំណត់ដោយអាជ្ញាធររាជធានី ខេត្ត។ ក្នុងករណីបេក្ខជនវិជ្ជមានកូវីដ-១៩ ត្រូវណែនាំឱ្យទៅទទួលការព្យាបាលស្របតាមវិធានវេជ្ជសាស្ត្រ និងមិនអនុញ្ញាតឱ្យចូលប្រឡងឡើយ ដើម្បីចៀសវាងការចម្លងជំងឺនៅក្នុងមណ្ឌលប្រឡង
- ផ្ដល់លិខិតបញ្ជាក់ដល់បេក្ខជនដែលអវិជ្ជមានកូវីដ-១៩ ក្រោយលទ្ធផលធ្វើតេស្តរហ័ស ដើម្បីយកទៅបង្ហាញនៅមណ្ឌលប្រឡង និងទទួលការអនុញ្ញាតឱ្យចូលប្រឡង
- រៀបចំទីតាំងផ្ដល់សេវាសុខាភិបាលសមស្រប សម្រាប់គណៈមេប្រយោគ និងបេក្ខជនដែលមានកម្ដៅលើសពី ៣៧.៥ អង្សាសេ និងមានបញ្ហាសុខភាពក្នុងដំណើរការសំណេរ។

## ៣- ក្រុមការងារសុខភាពប្រចាំមណ្ឌលសំណេរ មណ្ឌលកំណែ និងមណ្ឌលស្រង់បូកពិន្ទុដោយកុំព្យូទ័រ

គណៈមេប្រយោគទូទាំងប្រទេសប្រចាំមណ្ឌលសំណេរ ប្រធានមណ្ឌលកំណែ និងប្រធានមណ្ឌលស្រង់បូកពិន្ទុដោយកុំព្យូទ័រ ត្រូវចាត់តាំងក្រុមការងារសុខភាពប្រចាំមណ្ឌល ពីក្នុងចំណោមគណៈមេប្រយោគ និងគណៈកម្មការនានា ដោយមានសមាសភាពចូលរួមពីតំណាងអាជ្ញាធរ ភ្នាក់ងារសុខាភិបាល ដើម្បីអនុវត្តគោលការណ៍ណែនាំប្រតិបត្តិឱ្យមានប្រសិទ្ធភាព។

## ខ.ទិធានការអនុវត្ត

### ១- មុនដំណើរការសំណេរ

### ១.១- ចំពោះគ្រឹះស្ថានសិក្សាដែលយកធ្វើជាមណ្ឌលប្រឡង

- ធ្វើអនាម័យ បោសសម្អាតបន្ទប់ អគារ បរិវេណ និងរៀបចំកន្លែងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ
- ម្ងាប់មេរោគលើតុ កៅអី ដៃទ្វារ បង្កាន់ដៃ ផ្ទៃរាបបន្ទប់ប្រឡង និងកន្លែងចាប់កាន់ញឹកញាប់
- ពិនិត្យលទ្ធភាពរៀបចំគំនូសគម្លាតសុវត្ថិភាពនៅក្នុងបរិវេណគ្រឹះស្ថានសិក្សា ព្រមទាំងរៀបចំតុ កៅអីសម្រាប់បេក្ខជនក្នុងបន្ទប់ប្រឡងនីមួយៗ ដោយរក្សាគម្លាតសុវត្ថិភាពយ៉ាងតិច ១,៥ម៉ែត្រ
- រៀបចំកន្លែងបិទបញ្ជីឈ្មោះបេក្ខជនឱ្យបានច្រើនទីតាំង ដើម្បីរក្សានូវគម្លាតសុវត្ថិភាពសម្រាប់បេក្ខជនមើលឈ្មោះរបស់ខ្លួន
- រៀបចំកន្លែងលាងសម្អាតដៃ និងបង្គន់អនាម័យដោយមានទឹក និងសាប៊ូប្រើប្រាស់ជាប្រចាំ
- ពិនិត្យលទ្ធភាពរៀបចំឧបករណ៍ការពាររន្ទះនៅតាមមណ្ឌលប្រឡងដែលមានហានិភ័យខ្ពស់។

### ១.២- ប្រធានមណ្ឌលសំណេរ

#### ➢ ពេលព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២១

- ទទួលនិងរៀបចំសម្ភារៈសុខភាពអនាម័យ ដូចជា ម៉ាស់ ទឹកអាល់កុល ឬអាល់កុលជែល អាវការពារសុវត្ថិភាព(PPE) ស្រោមដៃ សាប៊ូ ជាពិសេសឧបករណ៍ស្ទង់កម្តៅ ស្ទីកឃ័រ -កម្តៅធម្មតា- ក្រោយពេលប្រជុំស្តាប់ការណែនាំអំពីយន្តការរដ្ឋបាល សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងបច្ចេកទេសពីប្រធានគណៈមេប្រយោគទូទាំងប្រទេសប្រចាំរាជធានី ខេត្ត រួច
- ត្រួតពិនិត្យបុគ្គលិកអប់រំដែលស្ថិតនៅក្នុងកំឡុងពេលចត្តាឡីស័ក ត្រូវបន្តការតាមដានសុខភាពដោយមិនអនុញ្ញាតឱ្យមកបំពេញភារកិច្ចនៅមណ្ឌលប្រឡងឡើយ
- ត្រួតពិនិត្យបេក្ខជនដែលបានធ្វើស្វ័យប្រកាសថា៖ បានប៉ះពាល់ផ្ទាល់ជាមួយអ្នកវិជ្ជមានកូវីដ-១៩ និងកំពុងស្ថិតនៅក្នុងកំឡុងពេលចត្តាឡីស័ក និងណែនាំបេក្ខជនឱ្យទៅធ្វើតេស្តរហ័សអង់ទីហ្សែនកូវីដ-១៩ នៅទីតាំងសុខាភិបាលដែលបានកំណត់ និងត្រូវយកលិខិតបញ្ជាក់បេក្ខជនអវិជ្ជមានកូវីដ-១៩ ពីភ្នាក់ងារសុខាភិបាល មកបង្ហាញនៅមណ្ឌលប្រឡងវិញ ដើម្បីទទួលការអនុញ្ញាតឱ្យចូលប្រឡង
- រៀបចំប្រគល់ភារកិច្ចនិងការទទួលខុសត្រូវជាលាយលក្ខណ៍អក្សរដល់ក្រុមការងារសុខភាពប្រចាំមណ្ឌលសំណេរ ដែលមានសមាសភាពជ្រើសរើសចេញពីគណៈមេប្រយោគ គណៈកម្មការនានា ជំនួយការអេប្បមាទ និងគ្រូពេទ្យប្រចាំការតាមមណ្ឌលនីមួយៗ ដឹកនាំដោយអនុប្រធានមណ្ឌលសំណេរ ០១រូប។

#### ➢ ពេលរសៀល ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១

- ផ្សព្វផ្សាយសេចក្តីណែនាំប្រតិបត្តិស្តីពី វិធានការសុខភាព និងសុវត្ថិភាព សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង៖ ២៧ ធ្នូ ២០២១ ដល់គណៈមេប្រយោគ និងគណៈកម្មការនានាក្នុងពេលប្រជុំណែនាំ និងណែនាំបន្ថែមដល់គណៈមេប្រយោគ និងគណៈកម្មការនានា ឱ្យវាស់កម្តៅ និងបិទស្ទីកឃ័រ -កម្តៅធម្មតា- លើស្លាកសញ្ញារបស់គណៈមេប្រយោគ និងគណៈកម្មការនានាក្រោយពេលប្រជុំចប់

- ណែនាំដល់គណៈមេប្រយោគ ឬគណៈកម្មការនានា ដែលមានកម្ដៅលើសពី៣៧.៥អង្សាសេ ទៅស្វែងរកសេវាព្យាបាលសមស្របនៅតាមទីតាំងសុខាភិបាលដែលមានរៀបចំ ប្រសិនបើបានធូរស្រាលសុខភាពជាប្រក្រតី ត្រូវត្រឡប់មកបំពេញភារកិច្ចវិញ
- ណែនាំដល់គណៈមេប្រយោគ ឬគណៈកម្មការនានាឱ្យ ៖
  - ទទួលទានដំណេក បរិភោគអាហារ និងទឹកស្អាតឱ្យបានគ្រប់គ្រាន់ប្រកបដោយសុវត្ថិភាព និងសុខភាព ពិសេសត្រូវទទួលទានអាហារពេលព្រឹក
  - ប្រកាន់ខ្ជាប់ក្បួនអនាម័យជាប្រចាំ ដូចជាអនាម័យខ្លួនប្រាណ សម្លៀកបំពាក់ និងកន្លែងស្នាក់នៅ ព្រមទាំងលាងសម្អាតដៃឱ្យបានញឹកញាប់
  - ត្រៀមបម្រុងសម្ភារៈអនាម័យដូចជាម៉ាស់ អាល់កុល ឬជែលលាងដៃ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួននៅពេលដំណើរការប្រឡង
  - ត្រៀមសម្ភារៈការពារកម្ដៅថ្ងៃនិងភ្លៀង ដូចជា មួក ឆ័ត្រ ឬអាវភ្លៀង សម្រាប់ប្រើប្រាស់នៅពេលធ្វើដំណើរទៅមណ្ឌលប្រឡង
  - ពាក់ម៉ាស់ឱ្យបានត្រឹមត្រូវគ្រប់ពេលធ្វើដំណើរនៅទីសាធារណៈ ទីកន្លែងបំពេញការងារ និងក្នុងពេលចាំបាច់
  - ហាមការធ្វើដំណើរទៅទីកន្លែងដែលមានមនុស្សប្រមូលផ្ដុំច្រើន កន្លែងចិញ្ចឹមឬលក់សត្វរស់ ឬ ទីកន្លែងដែលមានហានិភ័យនៃការចម្លងជំងឺកូវីដ-១៩
  - ហាមប្រើប្រាស់គ្រឿងស្រវឹង ផលិតផលថ្នាំជក់ ឬកេសជ្ជៈដែលប៉ះពាល់ដល់សុខភាព
  - ស្វែងរកកន្លែងស្នាក់នៅ និងកន្លែងទទួលទានអាហារប្រកបដោយសុវត្ថិភាព
  - គោរពច្បាប់ចរាចរ និងបើកបរដោយប្រុងប្រយ័ត្នក្នុងពេលធ្វើដំណើរទៅមណ្ឌលប្រឡង ដើម្បីជៀសវាងគ្រោះថ្នាក់កើតឡើងដោយថាហេតុ។

## ១.៣- ក្រុមការងារសុខភាព

### ➢ ពេលរសៀលថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២១

- រៀបចំបន្ទប់សុខភាព ដោយបំពាក់នូវសម្ភារៈចាំបាច់សម្រាប់សង្គ្រោះបឋម និងបន្ទប់ប្រឡងបម្រុងដោយឡែកសម្រាប់បេក្ខជនដែលមានកម្ដៅលើសពី៣៧,៥អង្សាសេ និងបន្ទប់ដោយឡែកសម្រាប់បេក្ខជនដែលស្ថិតក្នុងកំឡុងពេលចត្តាឡីស័ក យ៉ាងតិចចំនួន ០២ បន្ទប់
- រៀបចំសម្ភារៈអនាម័យដូចជាសាប៊ូ អាល់កុល ឬជែលលាងដៃ និងសម្ភារៈការពារសុវត្ថិភាព ដូចជាអាវការពារសុវត្ថិភាព(PPE) ស្រោមដៃ ម៉ាស់ សម្ភារម្លាប់មេរោគ សម្រាប់គណៈមេប្រយោគ និងគណៈកម្មការនានា ប្រើប្រាស់ពេលបំពេញភារកិច្ចរបស់ខ្លួន ជាពិសេសបន្ទប់ប្រឡងដោយឡែកសម្រាប់បេក្ខជនមានកម្ដៅលើសពី៣៧,៥អង្សាសេ និងបន្ទប់ដោយឡែកសម្រាប់បេក្ខជនដែលស្ថិតក្នុងកំឡុងពេលចត្តាឡីស័ក
- រៀបចំឧបករណ៍ ស្ទីកឃ័រ «កម្ដៅធម្មតា» និងកំណត់ទីកន្លែងនៅទីតាំងសមស្របក្នុងបរិវេណមណ្ឌលប្រឡងសម្រាប់ស្ទង់កម្ដៅគណៈមេប្រយោគ គណៈកម្មការនានា និងបេក្ខជន
- រៀបចំចងខ្សែកំណត់ទីតាំងគម្លាតសុវត្ថិភាព ដាក់បង្ហាញនូវសញ្ញា និងទិសដៅនៃការចល័តចេញចូល នៅក្នុងបរិវេណមណ្ឌលប្រឡង ដោយរក្សាគម្លាតយ៉ាងតិចបំផុត ១,៥ម៉ែត្រ

- រៀបចំឱ្យមានក្រុមគ្រូពេទ្យប្រចាំការ ដើម្បីចាត់វិធានការសង្គ្រោះស្របតាមវិធានវេជ្ជសាស្ត្ររបស់ក្រសួងសុខាភិបាល។

> **ពេលព្រឹក និងពេលរសៀល ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១**

- រៀបចំស្ទង់កម្តៅ និងត្រួតពិនិត្យសុខភាពបេក្ខជន ដែលមកមើលឈ្មោះនៅតាមមណ្ឌលសំណេរនីមួយៗ គណៈមេប្រយោគ និងគណៈកម្មការនានាទាំងអស់ ដោយបែងចែកជា៖
    - **ពេលព្រឹក និងរសៀលស្ទង់កម្តៅសម្រាប់បេក្ខជនមកពិនិត្យឈ្មោះ និង**
    - **ពេលរសៀលស្ទង់កម្តៅសម្រាប់គណៈមេប្រយោគចូលរួមប្រជុំ**
- ករណីរកឃើញកម្តៅធម្មតា (ក្រោមឬស្មើ៣៧,៥ អង្សាសេ) ត្រូវបិទស្ទីកឃ័រពណ៌ខៀវ «កម្តៅធម្មតា» លើអត្តសញ្ញាណបេក្ខជន បណ្ណសម្គាល់ខ្លួនសិស្ស ឬសលាកបត្រឯកត្តជន និងបិទស្ទីកឃ័រពណ៌ស្វាយ «កម្តៅធម្មតា» សម្រាប់គណៈមេប្រយោគ ឬគណៈកម្មការនានា
- ករណីរកឃើញបេក្ខជនមានកម្តៅលើសពី៣៧,៥អង្សាសេ ឬមានរោគសញ្ញាដូចជាក្អក ហៀរសំបោរ ឈឺបំពង់ក ពិបាកដកដង្ហើម ត្រូវណែនាំឱ្យធ្វើតេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩ នៅតាំងសុខាភិបាលដែលកំណត់ដោយអាជ្ញាធររាជធានី ខេត្ត និងត្រូវសុំលិខិតបញ្ជាក់បេក្ខជនអវិជ្ជមានកូវីដ-១៩ មកបង្ហាញនៅមណ្ឌលប្រឡងវិញ ដើម្បីទទួលស្ទីកឃ័រ«កម្តៅធម្មតា» និងការអនុញ្ញាតឱ្យចូលប្រឡង
- ករណីរកឃើញគណៈមេប្រយោគ ឬគណៈកម្មការនានាមានកម្តៅលើសពី៣៧,៥អង្សាសេ ឬមានរោគសញ្ញាដូចជាក្អក ហៀរសំបោរ ឈឺបំពង់ក ពិបាកដកដង្ហើម ត្រូវណែនាំឱ្យទៅរកសេវាសុខាភិបាលសមស្របនៅតាមទីតាំងដែលបានកំណត់ និងត្រូវបន្តការតាមដានសុខភាពដោយមិនអនុញ្ញាតអោយមកបំពេញភារកិច្ចនៅមណ្ឌលប្រឡងឡើយ
- ណែនាំបេក្ខជនដែលមានកម្តៅលើសពី៣៧,៥អង្សាសេ ឬមានបញ្ហាសុខភាព ហើយទទួលបានការបញ្ជាក់អវិជ្ជមានកូវីដ-១៩ ពីភ្នាក់ងារសុខាភិបាល ឱ្យត្រឡប់មកមណ្ឌលប្រឡងវិញ នាព្រឹកថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ មុនបេក្ខជនទូទៅ ដើម្បីស្ទង់កម្តៅជាថ្មីម្តងទៀត និងបញ្ជាក់ថាស្ថានភាពសុខភាពបានធូរស្រាលហើយ។

## ២- ក្នុងដំណើរការសំណេរ

### ២.១- ក្រុមការងារសុខភាព

> **មុនពេលចូលបរិវេណមណ្ឌលប្រឡង និងបន្ទប់ប្រឡង**

- រៀបចំឱ្យបេក្ខជនដែលស្ថិតនៅក្នុងកំឡុងពេលចត្តាឡីស័កបានទទួលការស្ទង់កំដៅ និងឆែកឆេរសំណៅឯកសារមុនគេ និងដាច់ដោយឡែកពីគេ រួចទើបដំណើរការស្ទង់កំដៅ និងឆែកឆេរសំណៅឯកសារបេក្ខជនទូទៅ
- ត្រួតពិនិត្យស្ទីកឃ័រ«កម្តៅធម្មតា»របស់បេក្ខជន គណៈមេប្រយោគ និងគណៈកម្មការនានាមុនអនុញ្ញាតឱ្យចូលមណ្ឌលប្រឡង
- រៀបចំអ្នកស្ទង់កម្តៅបេក្ខជន គណៈមេប្រយោគ និងគណៈកម្មការនានា នៅក្នុងបរិវេណមណ្ឌលប្រឡង ក្រោយពីឆែកឆេរសំណៅឯកសារ។ ក្នុងករណីរកឃើញអ្នកមានកម្តៅលើសពី៣៧,៥ អង្សាសេ ត្រូវ៖

- ស្ទង់កម្តៅម្តងទៀតជាលើកទី២ក្រោយ រយៈពេល៥នាទី និងអនុញ្ញាតឱ្យចូលបន្ទប់ប្រឡងនិងកន្លែងបំពេញភារកិច្ចរបស់ខ្លួន ប្រសិនបើកម្តៅចុះធម្មតាវិញ
- ករណីដែលស្ទង់កម្តៅលើកទី២នៅតែខ្ពស់លើសពី៣៧,៥អង្សាសេ ដដែល ចំពោះបេក្ខជនត្រូវបញ្ជូនគាត់ទៅបន្ទប់ប្រឡងដាច់ដោយឡែក ដែលបានត្រៀមបម្រុងទុក (រក្សាលេខតុលេខបន្ទប់ដដែល និងបញ្ជូនសន្លឹកកិច្ចការរបស់បេក្ខជនដាក់នៅក្នុងដុំកិច្ចការបេក្ខជននៅបន្ទប់ដើមតាមម៉ោងមុខវិជ្ជានីមួយៗ)។ ដោយឡែកចំពោះគណៈមេប្រយោគ និងគណៈកម្មការនានា ត្រូវអនុញ្ញាតឱ្យឈប់សម្រាកនិងណែនាំឱ្យរកសេវាសុខភាពសមស្រប។

- ណែនាំបេក្ខជន គណៈមេប្រយោគ និងគណៈកម្មការនានា ឱ្យលាងសម្អាតដៃជាមួយសាប៊ូ អាល់កុល ឬជែលលាងដៃ មុនពេលទៅបន្ទប់ប្រឡង ឬអនុវត្តភារកិច្ចរៀងៗខ្លួន
- ត្រួតពិនិត្យ និងណែនាំដល់បេក្ខជន គណៈមេប្រយោគ និងគណៈកម្មការនានាអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានសុខភាព សុវត្ថិភាព ក្នុងករណីមានបញ្ហាមិនស្រួលខ្លួនត្រូវជួបពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាលប្រចាំការនៅតាមមណ្ឌលប្រឡង។

## ២.២- គណៈមេប្រយោគ គណៈកម្មការនានា

### ➢ មុនពេលចូលបន្ទប់ប្រឡង

- ណែនាំឱ្យបេក្ខជនតម្រង់ជួរដោយរក្សាគម្លាតសុវត្ថិភាព និងពាក់ម៉ាស់ឱ្យបានត្រឹមត្រូវជាប្រចាំនៅក្នុងមណ្ឌលប្រឡង លើកលែងតែពេលផ្ទៀងផ្ទាត់មុខបេក្ខជនជាមួយសលាកបត្រ
- បើកទ្វារបង្អួចបន្ទប់ប្រឡងឱ្យមានខ្យល់ ពន្លឺគ្រប់គ្រាន់ និងរក្សាសីតុណ្ហភាពក្នុងបន្ទប់ប្រឡងមិនឱ្យទាបជាង២៤អង្សាសេ ចំពោះបន្ទប់ដែលប្រើម៉ាស៊ីនត្រជាក់
- ប្រើប្រាស់សម្ភារៈការពារសុវត្ថិភាព(PPE)កម្រិត២ សម្រាប់គណៈមេប្រយោគដែលបំពេញការងារនៅបន្ទប់បេក្ខជនមានកម្តៅលើសពី៣៧,៥អង្សាសេ និងបេក្ខជនដែលស្ថិតក្នុងកំឡុងពេលចត្តាឡីស័ក។

### ➢ ក្នុងពេលដំណើរការសំណេរ

- ពាក់ម៉ាស់ឱ្យបានត្រឹមត្រូវជាប្រចាំនៅក្នុងមណ្ឌលប្រឡង និងចៀសវាងយកដៃប៉ះលើផ្ទៃមុខ
- រក្សាគម្លាតសុវត្ថិភាពយ៉ាងតិច១,៥ម៉ែត្រ និងហាមឃាត់ការប៉ះពាល់គ្នាដោយផ្ទាល់ ដូចជាការចាប់ដៃ ឬប្រើប្រាស់របស់របររួមគ្នា
- អនុវត្តការរក្សាអនាម័យឱ្យបានត្រឹមត្រូវ ជាពិសេសត្រូវលាងសម្អាតដៃរៀងរាល់ពេលសម្រាកឆ្លងវិញ្ញាសា
- ណែនាំឱ្យបេក្ខជនគ្រប់គ្រងអារម្មណ៍ឱ្យបាននឹងន និងមានភាពក្លាហាន ករណីមានបញ្ហាមិនស្រួលខ្លួនត្រូវជួបពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាលប្រចាំការនៅតាមមណ្ឌលប្រឡង។

### ➢ ក្រោយដំណើរការសំណេរ

- ប្រើស្រោមដៃក្នុងការវេចខ្ចប់សន្លឹកកិច្ចការបេក្ខជន ដោយឡែកដុំសន្លឹកកិច្ចការដែលបានបញ្ចូលសន្លឹកកិច្ចការរបស់បេក្ខជនមានកម្តៅលើសពី ៣៧,៥អង្សាសេ និងបេក្ខជនដែលកំពុងស្ថិតក្នុងកំឡុងពេលចត្តាឡីស័ក ត្រូវវេចខ្ចប់ជាមួយថង់សុវត្ថិភាពដែលបានផ្តល់ជូន និងម្ញាប់មេរោគផ្ទៃខាងក្រៅថង់ក្រោយពេលវេចខ្ចប់រួច

- រម្ងាប់មេរោគលើតុ កៅអី ដៃទ្វារ បង្កាន់ដៃ ផ្ទៃរាប និងកន្លែងចាប់កាន់ញឹកញាប់ ក្រោយបញ្ចប់ដំណើរការសំណេរពេលព្រឹក និងពេលរសៀល និងមុនពេលចាកចេញពីបន្ទប់ប្រឡង ជាពិសេសបន្ទប់បេក្ខជនមានកម្តៅលើសពី៣៧,៥អង្សាសេ និងបន្ទប់បេក្ខជនដែលស្ថិតក្នុងកំឡុងពេលចត្តាឡីស័ក
- រៀបចំប្រមូល វេចខ្ចប់ និងទុកដាក់សម្រាមអោយបានត្រឹមត្រូវ ពិសេសម៉ាស់ និងសម្ភារៈការពារសុវត្ថិភាព(PPE) ដែលបានប្រើប្រាស់រួច។

## ៣- ដំណើរការកំណែ

### ៣.១- មុនដំណើរការកំណែ

➢ **ចំពោះគ្រឹះស្ថានសិក្សាដែលយកធ្វើជាមណ្ឌលកំណែ**

- ធ្វើអនាម័យ បោសសម្អាតបន្ទប់ អគារ បរិវេណនិងរៀបចំកន្លែងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ
- រៀបចំកន្លែងលាងសម្អាតដៃ និងបង្គន់អនាម័យដោយមានទឹកនិងសាប៊ូជាប្រចាំ
- រម្ងាប់មេរោគលើតុ កៅអី ដៃទ្វារ បង្កាន់ដៃ ផ្ទៃរាបបន្ទប់កំណែ និងកន្លែងចាប់កាន់ញឹកញាប់
- ពិនិត្យលទ្ធភាពរៀបចំគំនូសគម្លាតសុវត្ថិភាពនៅក្នុងបរិវេណគ្រឹះស្ថានសិក្សា
- រៀបចំតុ កៅអី សម្រាប់គណៈកម្មការកំណែក្នុងបន្ទប់កំណែ ដោយរក្សាគម្លាតសុវត្ថិភាពយ៉ាងតិច១,៥ម៉ែត្រ។

➢ **ប្រធានមណ្ឌលកំណែ**

- រៀបចំប្រគល់ភារកិច្ចនិងការទទួលខុសត្រូវជាលាយលក្ខណ៍អក្សរ ដល់ក្រុមការងារសុខភាពជ្រើសរើសចេញពីគណៈកម្មការកំណែ និងគណៈកម្មការនានា ដឹកនាំដោយប្រធាន ឬអនុប្រធានមណ្ឌលកំណែ
- ត្រួតពិនិត្យលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩ របស់គណៈកម្មការកំណែ និងគណៈកម្មការនានាទាំងអស់ ដើម្បីបញ្ជាក់ថា មិនមានគណៈកម្មការណាម្នាក់មានវិជ្ជមានជំងឺកូវីដ-១៩ ឬមិនទាន់បានធ្វើតេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩
- ផ្សព្វផ្សាយសេចក្តីណែនាំប្រតិបត្តិស្តីពីវិធានការសុខភាព និងសុវត្ថិភាព សម្រាប់ការប្រឡង សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិសម័យប្រឡង៖២៧ ធ្នូ ២០២១ ដល់គណៈកម្មការកំណែ និងគណៈកម្មការនានាក្នុងពេលប្រជុំណែនាំ និងណែនាំបន្ថែមដល់គណៈកម្មការកំណែ និងគណៈកម្មការនានា ឱ្យវាស់កម្តៅ និងបិទស្ទីកឃ័រ «កម្តៅធម្មតា» លើស្លាកសញ្ញារបស់គណៈកម្មការកំណែ និងគណៈកម្មការនានាក្រោយពេលប្រជុំចប់
- ណែនាំដល់គណៈកម្មការកំណែ គណៈកម្មការនានាដែលមានកម្តៅលើសពី៣៧,៥អង្សាសេ ឱ្យឈប់សម្រាកនិងទៅស្វែងរកសេវាព្យាបាលសមស្រប បើបានធូរស្រាលសុខភាពជាប្រក្រតី ត្រូវត្រឡប់មកបំពេញភារកិច្ចវិញ
- ណែនាំដល់គណៈមេប្រយោគកំណែ ឬគណៈកម្មការនានាឱ្យ ៖
    - ទទួលទានដំណេក បរិភោគអាហារ និងទឹកស្អាតឱ្យបានគ្រប់គ្រាន់ប្រកបដោយសុវត្ថិភាព និងសុខភាព ពិសេសត្រូវទទួលទានអាហារពេលព្រឹក

- ប្រកាន់ខ្ជាប់ក្បួនអនាម័យជាប្រចាំ ដូចជាអនាម័យខ្លួនប្រាណ សម្លៀកបំពាក់ និងកន្លែងស្នាក់នៅ ព្រមទាំងលាងសម្អាតដៃឱ្យបានញឹកញាប់
- ត្រៀមបម្រុងសម្ភារៈអនាម័យដូចជាម៉ាស់ អាល់កុល ឬជែលលាងដៃ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួននៅពេលដំណើរការប្រឡង
- ត្រៀមសម្ភារៈការពារកម្ដៅថ្ងៃនិងភ្លៀង ដូចជា មួក ឆ័ត្រ ឬអាវភ្លៀង សម្រាប់ប្រើប្រាស់នៅពេលធ្វើដំណើរទៅមណ្ឌលប្រឡង
- ពាក់ម៉ាស់ឱ្យបានត្រឹមត្រូវគ្រប់ពេលធ្វើដំណើរនៅទីសាធារណៈ ទីកន្លែងបំពេញការងារ និងក្នុងពេលចាំបាច់
- ហាមការធ្វើដំណើរទៅទីកន្លែងដែលមានមនុស្សប្រមូលផ្តុំច្រើន កន្លែងចិញ្ចឹមឬលក់សត្វរស់ ឬ ទីកន្លែងដែលមានហានិភ័យនៃការចម្លងជំងឺកូវីដ-១៩
- ហាមប្រើប្រាស់គ្រឿងស្រវឹង ផលិតផលថ្នាំជក់ ឬគេសជ្ជៈដែលប៉ះពាល់ដល់សុខភាព
- ស្វែងរកកន្លែងស្នាក់នៅនិងកន្លែងទទួលទានអាហារប្រកបដោយសុវត្ថិភាព
- គោរពច្បាប់ចរាចរ និងបើកបរដោយប្រុងប្រយ័ត្នក្នុងពេលធ្វើដំណើរទៅមណ្ឌលប្រឡង ដើម្បីជៀសវាងគ្រោះថ្នាក់កើតឡើងជាយថាហេតុ

- ចាត់ចែងរម្ងាប់មេរោគសន្លឹកកិច្ចការបេក្ខជនមានកម្ដៅលើសពី៣៧,៥អង្សាសេ និងបេក្ខជនដែលស្ថិតក្នុងកំឡុងពេលចត្តាឡីស័ក អោយបានរួចរាល់មុននឹងចរាចរសន្លឹកកិច្ចការបេក្ខជនទៅតាមនីតិវិធីកំណែ។

➢ **ចំពោះក្រុមការងារសុខភាពមណ្ឌលកំណែ**

- រៀបចំបន្ទប់សុខភាព ដោយបំពាក់នូវសម្ភារៈចាំបាច់សម្រាប់សង្គ្រោះបឋម
- រៀបចំឱ្យមានក្រុមគ្រូពេទ្យប្រចាំការ ដើម្បីចាត់វិធានការសង្គ្រោះតាមពិធីសារវេជ្ជសាស្ត្ររបស់ក្រសួងសុខាភិបាល
- រៀបចំសម្ភារៈអនាម័យដូចជាសាប៊ូ អាល់កុល ឬជែលលាងដៃ និងត្រៀមសម្ភារៈការពារសុវត្ថិភាព ដូចជា ស្រោមដៃ ម៉ាស់ សម្ភារៈរម្ងាប់មេរោគ សម្រាប់គណៈកម្មការកំណែ និងគណៈកម្មការនានាប្រើប្រាស់ពេលបំពេញភារកិច្ចរបស់ខ្លួន
- រៀបចំឧបករណ៍ ស្ទីកឃ័រ «កម្ដៅធម្មតា» និងកំណត់ទីកន្លែងនៅទីតាំងសមស្របក្នុងបរិវេណមណ្ឌលកំណែ សម្រាប់ស្ទង់កម្ដៅគណៈកម្មការកំណែ និងគណៈកម្មការនានា
- វាស់កម្ដៅ និងបិទស្ទីកឃ័រ «កម្ដៅធម្មតា» លើស្លាកសញ្ញារបស់គណៈកម្មការកំណែ និងគណៈកម្មការនានាក្រោយពេលប្រជុំណែនាំចប់។ ក្នុងករណីអ្នកមានកម្ដៅលើសពី៣៧,៥អង្សាសេឡើងទៅ ត្រូវណែនាំឱ្យឈប់សម្រាកនិងរកសេវាព្យាបាលសមស្រប នៅពេលបានធូរស្រាលសុខភាពជាប្រក្រតី ត្រូវត្រឡប់មកបំពេញភារកិច្ចវិញ។

## ៣.២- ក្នុងពេលដំណើរការកំណែ

> **ក្រុមការងារសុខភាពមណ្ឌលកំណែ**

- ត្រួតពិនិត្យស្ទើកយ័រ-កម្តៅឥម្មតា-របស់គណៈកម្មការកំណែ និងគណៈកម្មការនានាមុនអនុញ្ញាតឱ្យចូលមណ្ឌលកំណែ ក្នុងករណីកម្តៅលើសពី៣៧,៥អង្សាសេ ត្រូវអនុញ្ញាតឱ្យឈប់សម្រាកនិងណែនាំឱ្យទៅរកសេវាសុខភាពសមស្រប
- ត្រួតពិនិត្យ និងណែនាំដល់គណៈកម្មការកំណែ និងគណៈកម្មការនានាអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានសុខភាព សុវត្ថិភាព ក្នុងករណីមានបញ្ហាមិនស្រួលខ្លួនត្រូវជួបពិគ្រោះយោបល់ជាមួយភ្នាក់ងារសុខាភិបាលប្រចាំការនៅតាមមណ្ឌលប្រឡង។

> **គណៈកម្មការកំណែទាំងអស់**

- ប្រើប្រាស់ស្រោមដៃជាប្រចាំសម្រាប់កំណែសន្លឹកកិច្ចការបេក្ខជន ដែលមានកម្តៅលើសពី៣៧,៥ អង្សាសេ និងបេក្ខជនដែលស្ថិតក្នុងកំឡុងពេលចត្តាឡីស័ក
- ពាក់ម៉ាស់ឱ្យបានត្រឹមត្រូវជាប្រចាំនៅក្នុងមណ្ឌលកំណែ និងចៀសវាងយកដៃប៉ះលើផ្ទៃមុខ
- រក្សាគម្លាតសុវត្ថិភាពយ៉ាងតិច១,៥ម៉ែត្រ និងហាមឃាត់ការប៉ះពាល់គ្នាដោយផ្ទាល់ ដូចជាការចាប់ដៃ ឬប្រើប្រាស់របស់របរួមគ្នា
- អនុវត្តការរក្សាអនាម័យឱ្យបានត្រឹមត្រូវ ជាពិសេសត្រូវលាងសម្អាតដៃរៀងរាល់ពេលសម្រាក
- ត្រូវជួបពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាលប្រចាំការនៅតាមមណ្ឌលកំណែ ក្នុងករណីមានបញ្ហាសុខភាព។

## ៤- ដំណើរការស្រង់ ប្លុកពិន្ទុ ដោយកុំព្យូទ័រ

## ៤.១- មុនដំណើរការស្រង់ ប្លុកពិន្ទុដោយកុំព្យូទ័រ

> **ចំពោះមណ្ឌលស្រង់ ប្លុកពិន្ទុដោយកុំព្យូទ័រ**

- ធ្វើអនាម័យ បោសសម្អាតបន្ទប់ អគារ បរិវេណនិងរៀបចំកន្លែងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ
- រៀបចំកន្លែងលាងសម្អាតដៃ និងបង្គន់អនាម័យដោយមានទឹកនិងសាប៊ូជាប្រចាំ
- សម្លាប់មេរោគលើតុ កៅអី ដៃទ្វារ បង្កាន់ដៃ ផ្ទៃរាបបន្ទប់ និងកន្លែងចាប់កាន់ញឹកញាប់
- ពិនិត្យលទ្ធភាពរៀបចំគំនូសគម្លាតសុវត្ថិភាពនៅក្នុងបរិវេណមណ្ឌល
- រៀបចំតុ កៅអី សម្រាប់គណៈកម្មការស្រង់ ប្លុកពិន្ទុដោយកុំព្យូទ័រដោយរក្សាគម្លាតសុវត្ថិភាពយ៉ាងតិច១,៥ម៉ែត្រ

> **ប្រធានគណៈកម្មការស្រង់ ប្លុកពិន្ទុដោយកុំព្យូទ័រ**

- រៀបចំប្រគល់ភារកិច្ចនិងការទទួលខុសត្រូវជាលាយលក្ខណ៍អក្សរ ដល់ក្រុមការងារសុខភាពជ្រើសរើសចេញពីគណៈកម្មការស្រង់ ប្លុកពិន្ទុដោយកុំព្យូទ័រដឹកនាំដោយប្រធានឬអនុប្រធានគណៈកម្មការស្រង់ ប្លុកពិន្ទុដោយកុំព្យូទ័រ
- ត្រួតពិនិត្យលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩ របស់គណៈកម្មការស្រង់ ប្លុកពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការនានាទាំងអស់ដើម្បីបញ្ជាក់ថា មិនមានគណៈកម្មការណាម្នាក់មានវិជ្ជមានជំងឺកូវីដ-១៩ ឬមិនទាន់បានធ្វើតេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩

- ផ្សព្វផ្សាយសេចក្ដីណែនាំប្រតិបត្តិស្ដីពី វិធានការសុខភាពនិងសុវត្ថិភាព សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិសម័យប្រឡង៖ ២៧ ធ្នូ ២០២១ ដល់គណៈកម្មការស្រង់ បូកពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការនានាក្នុងពេលប្រជុំណែនាំ និងណែនាំបន្ថែមដល់គណៈកម្មការស្រង់ បូកពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការនានា ឱ្យវាស់កម្ដៅ និងបិទស្ទីកឃ័រ «កម្ដៅធម្មតា» លើស្លាកសញ្ញារបស់គណៈកម្មការស្រង់ បូកពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការនានាមុនពេលបំពេញការងារ
- ត្រូវណែនាំដល់គណៈកម្មការស្រង់ បូកពិន្ទុដោយកុំព្យូទ័រ ឬគណៈកម្មការនានា ដែលមានកម្ដៅលើសពី៣៧,៥អង្សាសេ ឱ្យឈប់សម្រាកនិងឱ្យរកទៅស្វែងរកសេវាព្យាបាលសមស្រប បើបានធូរស្រាលសុខភាពជាប្រក្រតី ត្រូវត្រឡប់មកបំពេញភារកិច្ចវិញ ។

➢ **ក្រុមការងារសុខភាពមណ្ឌលស្រង់ បូកពិន្ទុដោយកុំព្យូទ័រ**
- រៀបចំបន្ទប់សុខភាព ដោយបំពាក់នូវសម្ភារៈចាំបាច់សម្រាប់សង្គ្រោះបឋម
- រៀបចំឱ្យមានក្រុមគ្រូពេទ្យប្រចាំការ ដើម្បីចាត់វិធានការសង្គ្រោះតាមពិធីសារវេជ្ជសាស្ត្ររបស់ក្រសួងសុខាភិបាល
- រៀបចំសម្ភារៈអនាម័យដូចជាសាប៊ូ អាល់កុល ឬជែលលាងដៃ និងត្រៀមសម្ភារៈការពារសុវត្ថិភាព ដូចជា ស្រោមដៃ ម៉ាស់ សម្ភារៈម្លាប់មេរោគ សម្រាប់គណៈកម្មការស្រង់ បូកពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការនានា ប្រើប្រាស់ពេលបំពេញភារកិច្ចរបស់ខ្លួន
- រៀបចំឧបករណ៍ ស្ទីកឃ័រ «កម្ដៅធម្មតា» និងកំណត់ទីតាំងសមស្របក្នុងបរិវេណមណ្ឌល សម្រាប់ស្ទង់កម្ដៅគណៈកម្មការស្រង់ បូកពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការនានា
- វាស់កម្ដៅ និងបិទស្ទីកឃ័រ «កម្ដៅធម្មតា» លើស្លាកសញ្ញារបស់គណៈកម្មការស្រង់ បូកពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការនានាមុនអនុញ្ញាតឱ្យចូលបំពេញភារកិច្ចរបស់ខ្លួនក្នុងករណីអ្នកមានកម្ដៅលើសពី ៣៧,៥អង្សាសេឡើងទៅ ត្រូវណែនាំឱ្យឈប់សម្រាកនិងឱ្យរកសេវាព្យាបាលសមស្រប បើបានធូរស្រាលសុខភាពជាប្រក្រតី ត្រូវត្រឡប់មកបំពេញភារកិច្ចវិញ។

## ៤.២- **ក្នុងដំណើរការស្រង់ បូកពិន្ទុ ដោយកុំព្យូទ័រ**

➢ **ក្រុមការងារសុខភាពមណ្ឌលស្រង់ បូកពិន្ទុដោយកុំព្យូទ័រ**
- ត្រួតពិនិត្យស្ទីកឃ័រ«កម្ដៅធម្មតា»របស់គណៈកម្មការស្រង់ បូកពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការនានាមុន អនុញ្ញាតឱ្យចូលមណ្ឌលស្រង់ បូកពិន្ទុដោយកុំព្យូទ័រ ក្នុងករណីករណីកម្ដៅលើសពី៣៧,៥អង្សាសេ ត្រូវអនុញ្ញាតឱ្យឈប់សម្រាកនិងណែនាំឱ្យរកសេវាសុខភាពសមស្រប
- ត្រួតពិនិត្យ និងណែនាំដល់គណៈកម្មការស្រង់ បូកពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការនានា អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានសុខភាព សុវត្ថិភាព ក្នុងករណីមានបញ្ហាមិនស្រួលខ្លួនត្រូវជួបពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាលប្រចាំការនៅមណ្ឌលស្រង់ បូកពិន្ទុដោយកុំព្យូទ័រ ។

➢ **គណៈកម្មការស្រង់ បូកពិន្ទុដោយកុំព្យូទ័រ ទាំងអស់**
- ពាក់ម៉ាស់ឱ្យបានត្រឹមត្រូវជាប្រចាំនៅក្នុងមណ្ឌលស្រង់ បូកពិន្ទុដោយកុំព្យូទ័រ
- រក្សាគម្លាតសុវត្ថិភាពយ៉ាងតិច១,៥ម៉ែត្រ និងហាមឃាត់ការប៉ះពាល់គ្នាដោយផ្ទាល់ ដូចជាការចាប់ដៃ ឬប្រើប្រាស់របស់របររួមគ្នា

- អនុវត្តការរក្សាអនាម័យឱ្យបានត្រឹមត្រូវ ជាពិសេសត្រូវលាងសម្អាតដៃរៀងរាល់ពេលសម្រាក
- ត្រូវជួបពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាលប្រចាំការនៅតាមមណ្ឌលស្រង់ បូកពិន្ទុដោយកុំព្យូទ័រ ក្នុងករណីមានបញ្ហាសុខភាព។

ទទួលបានសេចក្តីណែនាំនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធានអង្គភាព ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ប្រធានក្រុមប្រឹក្សាភិបាល នាយក នាយិកា គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន បុគ្គលិកអប់រំដែលជាគណៈមេប្រយោគ គណៈកម្មការនានាទាំងដំណើរការសំណេរ កំណែ និងស្រង់ បូកពិន្ទុដោយកុំព្យូទ័រ និងប្រធានមណ្ឌល ត្រូវអនុវត្តសេចក្តីណែនាំប្រតិបត្តិនេះឱ្យបានល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។/

ថ្ងៃពុធ ១១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល ៖**

- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានអប់រំ
- អគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត

*-ដើម្បីជូនជ្រាបនិងសហការ-*

- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង
- មន្ទីរ អ.យ.ក. រាជធានី ខេត្ត
- គ្រប់គ្រឹះស្ថានសិក្សា ដែលជាមណ្ឌលប្រឡង និងកំណែ

*-ដើម្បីអនុវត្ត-*

- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានសុខភាពសិក្សា